**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៧៣ ២៥ ក.ប/ប្រក.ក.វ.ក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការដោះស្រាយវិវាទបុគ្គល

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២០/០០១ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

### ប្រការ១._

គ្រប់រឿងវិវាទបុគ្គល ភាគីណាមួយអាចប្តឹងទៅអធិការការងារ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។

ពាក្យបណ្តឹងអាចដាក់នៅនាយកដ្ឋានវិវាទការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីខេត្ត នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

### ប្រការ២._

ក្រោយពីបានទទួលពាក្យបណ្តឹង អធិការការងារនឹងពិនិត្យមើលសំណុំរឿង ដើម្បីចាត់វិធានការបន្តជាអាទិ៍៖

- ផ្សះផ្សា ឬ
- ចុះធ្វើអធិការកិច្ចការងារ។

### ប្រការ៣._

អធិការការងារត្រូវធ្វើលិខិតអញ្ជើញទៅភាគីវិវាទមកផ្តល់នូវព័ត៌មាន និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីជាមូលដ្ឋានក្នុងការផ្សះផ្សា។

ការសាកសួរព័ត៌មានពីភាគីវិវាទ ត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នា។ គ្រប់ពេលសាកសួរព័ត៌មានត្រូវធ្វើកំណត់ហេតុដោយមានចុះហត្ថលេខារបស់អធិការការងារ និងចុះហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគីដែលផ្តល់ព័ត៌មាននោះហើយកំណត់ហេតុនេះត្រូវផ្តល់ជូនភាគីដែលផ្តល់ព័ត៌មាន១ (មួយ) ច្បាប់។

ក្នុងករណីដើមចោទ ឬតំណាងនៃជននេះ មិនបានមកផ្តល់ព័ត៌មានតាមកាលកំណត់ ឬក្នុងរយៈពេល ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ យ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ ដោយគ្មានមូលហេតុសមរម្យទេនោះ ពាក្យបណ្តឹងនោះត្រូវទុកជាមោឃៈ។

ក្នុងករណីចុងចម្លើយ ឬតំណាងនៃជននេះមិនបានចូលបង្ហាញខ្លួនតាមកាលកំណត់ ឬក្នុងរយៈពេល ៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ យ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ ដោយគ្មានមូលហេតុសមរម្យទេនោះ ត្រូវចាត់ទុកថាការផ្សះផ្សាមិនសះជា ហើយចុងចម្លើយ ត្រូវចាត់ទុកថាមានកំហុសដូចការចោទប្រកាន់។

### ប្រការ៤._

បន្ទាប់ពីបានទទួលព័ត៌មានសព្វគ្រប់អស់ហើយ អធិការការងារត្រូវធ្វើលិខិតអញ្ជើញម្តងទៀតឱ្យភាគីទាំងសងខាងចូលរួមប្រជុំជាមួយគ្នាដើម្បីធ្វើការផ្សះផ្សា។

អធិការការងារត្រូវធ្វើការផ្សះផ្សាវិវាទបុគ្គលក្នុងរយៈពេល៣ (បី) សប្តាហ៍យ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

ក្នុងករណីដើមចោទ ឬតំណាងនៃជននេះមិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមរម្យទេនោះ ឬមិនចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើកំណត់ហេតុ ពាក្យបណ្តឹងត្រូវចាត់ទុកជាមោឃៈ។

ក្នុងករណីចុងចម្លើយ ឬតំណាងនៃជននេះមិនចូលរួមប្រជុំតាមការកំណត់ដោយគ្មានបញ្ជាក់មូលហេតុសមរម្យ ត្រូវចាត់ទុកថាការផ្សះផ្សាមិនសះជា ហើយចុងចម្លើយត្រូវចាត់ទុកថាមានកំហុសដូចការចោទប្រកាន់។

**ប្រការ៥._**

ពាក្យបណ្តឹងដែលត្រូវបានចាត់ទុកជាមោឃៈ ដូចមានកំណត់ក្នុងប្រការ៣ និងប្រការ៤ នៃប្រកាសនេះ មិនអាចត្រូវបានទទួលយកមកចាត់ការក្នុងនីតិវិធីនៃការផ្សះផ្សានោះទេ ក្នុងករណីមានការដាក់ពាក្យបណ្តឹងសាជាថ្មី។

**ប្រការ៦._**

លិខិតអញ្ជើញដែលមានចែងក្នុងប្រការ៣ និងប្រការ៤ ខាងលើ ត្រូវផ្ញើជូនភាគីតាមលិខិតអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃ ដែលមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃបញ្ជាក់ថាបានទទួលហើយ ឬតាមមធ្យោបាយផ្សេងទៀតដែលទុកជាបានការ។

**ប្រការ៧._**

អធិការការងារត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់ព្រមសះជានឹងគ្នា។ កំណត់ហេតុនោះ ត្រូវចុះហត្ថលេខាដោយអធិការការងារ ព្រមទាំងហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគីវិវាទ និងត្រូវចម្លងជូនភាគីវិវាទផង។

ការព្រមព្រៀងដែលបានធ្វើនៅចំពោះមុខអធិការការងារ គឺជាការព្រមព្រៀងយកជាការបានចំពោះមុខច្បាប់។

**ប្រការ៨._**

ក្នុងរយៈពេល២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីការផ្សះផ្សាវិវាទការងារមិនសះជា ភាគីវិវាទអាចស្នើសុំជាលាយលក្ខណ៍អក្សររួមគ្នាមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្សះផ្សាសាឡើងវិញ។

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈអាចចាត់តាំង ឬប្តូរអ្នកផ្សះផ្សាដើម្បីផ្សះផ្សាវិវាទការងារនេះសាឡើងវិញបានស្របតាមនីតិវិធី ដែលមានចែងក្នុងប្រកាសនេះ។

ប្រសិនបើការផ្សះផ្សាវិវាទការងារសាឡើងវិញនេះមិនទទួលបានលទ្ធផលសះជា ភាគីវិវាទមិនអាចស្នើសុំឱ្យផ្សះផ្សាសាឡើងវិញម្តងទៀតបានទេ ដោយត្រូវអនុវត្តតាមនីតិវិធីបន្តសម្រាប់ការដោះស្រាយវិវាទការងារ។

**ប្រការ៩._**

បន្ទាប់ពីការផ្សះផ្សាមិនសះជានឹងគ្នា ភាគីវិវាទអាចប្តឹងទៅតុលាការការងារក្នុងរយៈពេល២ (ពីរ) ខែ។ ប៉ុន្តែ ក្នុងករណីមានការស្នើសុំពីភាគីវិវាទក្នុងអំឡុងពេលផ្សះផ្សា អធិការការងារត្រូវរាយការណ៍ក្នុងរយៈពេល២ (ពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ជូនរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីមានចំណាត់ការបន្តទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេល៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ។

គ្រប់វិវាទបុគ្គល អាចត្រូវបានប្ដឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលស្របតាមនីតិវិធីដូចមានចែងក្នុងកថាខណ្ឌខាងលើ លើកលែងតែវិវាទដែលត្រូវបានចាត់ទុកជាមោឃៈដោយអធិការការងារ។

**ប្រការ១០.-**

ប្រកាសលេខ៣១៨ សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១ ស្ដីពីនីតិវិធីនៃការដោះស្រាយវិវាទបុគ្គល របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ